## មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0120**

### សម្ភាសន៍ជាមួយឈ្មោះ ស៊ុន ម៉ាច ភេទស្រី អាយុ៨៨ឆ្នាំ
### មុខងារជំនាន់ខ្មែរក្រហម“កងចល័ត”
### រស់នៅភូមិបន្ទាយឆ្មារខាងលិច ឃុំបន្ទាយឆ្មា ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ
### ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១០
### សម្ភាសន៍ដោយៈ សុខ វណ្ណៈ
### ០០:៣៤:១០
### ១៤ទំព័រ

វណ្ណៈ: ចឹងជាដំបូងខ្ញុំប្រាប់ឈ្មោះថា ខ្ញុំឈ្មោះ សុខ វណ្ណៈ ។

ម៉ាចៈ ចាស ។

វណ្ណៈ: ខ្ញុំមកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា?

ម៉ាចៈ ចាស ។

វណ្ណៈ: ហើយខ្ញុំបានមកដល់ភូមិឃុំរបស់មីងក៏ដោយសារខ្ញុំចង់ដឹងរឿងរ៉ាវទាក់ទងពីប្រវត្តិភូមិឃុំនិងទាក់ទងនិងបងប្អូនដែលធ្លាប់ឆ្លងកាត់ក្នុងសម័យខ្មែរក្រហមណាស់មីង?

ម៉ាចៈ ចាស ។

វណ្ណៈ: ហើយបទសម្ភាសន៍ខ្ញុំជាមួយមីង តើមីងអនុញ្ញាតឲ្យខ្ញុំយកទៅសរសេរជាអត្ថបទអីបានទេមីង?

ម៉ាចៈ ខ្ញុំមិនសូវចេះរ៉ៃរ៉ាប់ផងព្រោះអីជំនាន់ប៉ុល ពតខ្ញុំនៅកងកុមារ ។

វណ្ណៈ: បាទ!មិនអីទេ គ្រាន់តែជាការសម្ភាសន៍ជាមួយមីងហ្នឹងអាចយកទៅសរសេរបាន?

ម៉ាចៈ ចាស!បានព្រោះសម័យប៉ុល ពតខ្ញុំកំសត់កម្រណាស់ម៉ែឪពុកស្លាប់អស់ ខ្ញុំកូនកព្រាខ្ញុំនៅតែជាមួយគេហ្នឹង ។

វណ្ណៈ: បាទ ។

ម៉ាចៈ នៅជាមួយមីងមារអត់មានឪពុកម្ដាយទេ ស្លាប់អស់ ។

វណ្ណៈ: ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះមីង?

ម៉ាចៈ ខ្ញុំឈ្មោះ ស៊ុន ម៉ាច ។

វណ្ណៈ: មីងអាយុប៉ុន្មានហើយ?

ម៉ាចៈ អាយុ៤៨លោកគ្រូ ។

វណ្ណៈ	ប្ដីឈ្មោះអីដែរ?

ម៉ាចៈ	ឈ្មោះ ផុត ។

វណ្ណៈ	ស្អីគេផុត?

ម៉ាចៈ	មួក ផុត ។

វណ្ណៈ	គាត់អាយុប៉ុន្មានហើយ?

ម៉ាចៈ	គាត់ជំណាក់មែអាយុប៉ុន្មានហើយអាយុ៣០ហើយ ។

វណ្ណៈ	អាយុប្អូនមីងទេ?

ម៉ាចៈ	ប្អូន អាយុ៣៦នេះហើយ៣៦លោកគ្រូ ។

វណ្ណៈ	មីងមានកូនប៉ុន្មាន?

ម៉ាចៈ	ខ្ញុំមានកូនពីរសុទ្ធតែប្រុស ។

វណ្ណៈ	ឪពុកមីងឈ្មោះអី?

ម៉ាចៈ	ឪពុកខ្ញុំឈ្មោះ ស៊ុន ។

វណ្ណៈ	ឪពុកត្រកូលគាត់ស្អី ស៊ុន?

ម៉ាចៈ	សេ ស៊ុន ឪគាត់ឈ្មោះ សេ ។

វណ្ណៈ	ចឹងម្ដាយឈ្មោះអីទៅ?

ម៉ាចៈ	ម្ដាយឈ្មោះ មុំ ម៉ន ។

វណ្ណៈ	ចឹងគាត់ទាំងពីរនៅរស់ដែរ?

ម៉ាចៈ	គាត់ស្លាប់តាំងពីសម័យប៉ុល ពតនោះ ស្លាប់ដោយសារអត់ឃ្លាន ។

វណ្ណៈ	ចឹងដោយសារអត់មានអាហារ?

ម៉ាចៈ	អត់ដាច់ពោះស្លាប់ អត់បាយជំនាន់ប៉ុល ពត ។

វណ្ណៈ	ចឹងចាំមើលខ្ញុំសម្ភាសន៍តាមហ្នឹង?

ម៉ាចៈ	ចាស ។

វណ្ណៈ	ចឹងខ្ញុំចង់សួរស្រុកកំណើតនៅភូមិអី?

ម៉ាចៈ	នៅភូមិសាហួយ ។

វណ្ណៈ	ឃុំ?

ម៉ាចៈ	ឃុំព្រៃស្វាយ ។

វណ្ណៈ	ស្រុក?

ម៉ាចៈ ស្រុកមោង ។

វណ្ណៈ ខេត្ត?

ម៉ាចៈ ខេត្តបាត់ដំបង ។ «អ្នកជិតខាងនិយាយថា មាននៅកំពតដែរ?» ទេ អានោះទៅលេង កាលខ្ញុំទៅលេងជាមួយបងប្អូន ទងសុខនៅចាហួយប្រឡោមផ្ទុកហ្នឹងតែម្តង ។

វណ្ណៈ ចឹងឥឡូវនៅភូមិអី?

ម៉ាចៈ នេះហ្នឹង ។

វណ្ណៈ បាទ ។

ម៉ាចៈ នៅបន្ទាយឆ្មា ។

វណ្ណៈ អត់មានខាងកើតខាងជើងទេ?

ម៉ាចៈ ភូមិបន្ទាយឆ្មាខាងលិច ។

វណ្ណៈ ឃុំ?

ម៉ាចៈ បន្ទាយឆ្មា ។

វណ្ណៈ ស្រុកថ្មពួក?

ម៉ាចៈ ចាស ។

វណ្ណៈ ខេត្តបន្ទាយមានជ័យ?

ម៉ាចៈ ចាស ។

វណ្ណៈ មីងរៀនបានត្រឹមណា?

ម៉ាចៈ ខ្ញុំជំនាន់ប៉ុល ពត វែកតែដីមិនបានរៀនផង ខ្ញុំទើបរៀនអក្ខរកម្មចាស់ៗហ្នឹង ។

វណ្ណៈ ចឹងរៀនចេះតិចតួច?

ម៉ាចៈ ចេះបានមើលរូបតិចៗលោកគ្រូ ។

វណ្ណៈ ចេះសរសេរទេ?

ម៉ាចៈ ចាស!ចេះសរសេរបន្តិចបន្តួចមិនចេះស្ទាត់ទេលោកគ្រូ ព្រោះអីទៅរៀនអក្ខរកម្មចាស់ ហើយវាងងឹតហើយដោតតែគូទម្ជុលមិនចង់ចូលផង ។

វណ្ណៈ ចឹងជំនាន់លន់ នល់មិនបានរៀនទេ?

ម៉ាចៈ ចាស!ជំនាន់ប៉ុល ពតវែកតែដីហ្នឹងហើយ ។

វណ្ណៈ ចឹងមីងមានបងប្អូនបង្កើតប៉ុន្មាននាក់?

ម៉ាចៈ បងប្អូនបង្កើតគាត់ស្លាប់អស់ហើយគាត់ធ្វើទាហានកាលពីជំនាន់ហេង សំរិនណាស់ គាត់ទៅវៃខាងបប៉ៃលិនស្លាប់អស់ហើយនៅតែខ្ញុំមួយកូនស្រី មានបងបួននាក់ធ្វើទាហានទាំងបួននាក់ស្លាប់អស់ហើយនៅតែម្នាក់ឯងហ្នឹង ។

វណ្ណៈ ចឹងទាហានរដ្ឋកម្ពុជាហ្នឹង?

ម៉ាចៈ ចាស ។

វណ្ណៈ ចឹងមីងសព្វថ្ងៃនៅតែម្នាក់ឯងទេ?

ម៉ាចៈ នៅតែម្នាក់ឯង ។

វណ្ណៈ ចឹងបងប្អូនជីដូនមួយសាច់ញាតិអីនៅខាងបាត់ដំបង?

ម៉ាចៈ នៅអីស្រុកណុងនៅឬស្សីក្រាំងឆ្កុកបវេលខាងបងប្អូនជីដូនមួយ ។

វណ្ណៈ ចឹងមីងមកនៅភូមិនេះតាំងពីឆ្នាំណាមក?

ម៉ាចៈ ខ្ញុំមកនៅតាំងពីសម័យកសិកម្មកាលគេចឹញ្ចឹមជ្រូកចិញ្ចឹមមាន់នេះហើយ មិនដឹងជាឆ្នាំណាកាលហ្នឹង កាលហ្នឹងគេកើតកសិកម្មឆ្នាំណាអាម៉ាកឆ្នាំគេបង្កើតកសិកម្មចិញ្ចឹមមាន់ចិញ្ចឹមជ្រូកហ្នឹងខ្ញុំមកនៅហ្នឹងឯង ។

វណ្ណៈ ចឹងកាលសម័យខ្មែរក្រហមបីឆ្នាំមីងនៅណា?

ម៉ាចៈ ខ្ញុំសម័យខ្មែរក្រហមបីឆ្នាំខ្ញុំនៅកំពត ខ្ញុំទៅរស់នៅតាមបងប្អូននៅនោះ ។

វណ្ណៈ ម៉េចបានជាទៅនៅកំពតវិញ?

ម៉ាចៈ ទៅនៅកំពតខ្ញុំទៅនៅតាមបងប្អូន ដល់មកពីរត់វៀតណាមឃើញខ្ញុំចូលទៅនៅខាងនោះខ្ញុំទៅលេងបងប្អូន ខ្ញុំទៅនៅបានបួនទៅប្រាំឆ្នាំបានខ្ញុំមកនៅស្រុកកំណើតនៅចាហួយនេះវិញ ។

វណ្ណៈ ចឹងចាំមើលណាស់ដំណាក់កាលទីមួយសម័យរដ្ឋប្រហារទម្លាក់សម្តេចសីហនុណាស់ ។

ម៉ាចៈ ចាស ។

វណ្ណៈ ឆ្នាំ៧០ ចឹង៧០-៧១-៧២-៧៣និង៧៤មីងនៅណា?

ម៉ាចៈ ខ្ញុំនៅតាមអ៊ំមីងមាអីស្រុកនោះហើយ ។

វណ្ណៈ នៅស្រុកមោងហ្នឹង?

ម៉ាចៈ នៅស្រុកមោងឬស្សីហ្នឹងហើយ នៅតាមអ៊ំមីងមាដល់គាត់មកលេងចឹងខ្ញុំទៅនៅជាមួយគាត់ ។

វណ្ណៈ ចឹងកាលឆ្នាំ១៩៧៥ខ្មែរក្រហមចូលកាន់កាប់ទូទាំងប្រទេសហ្នឹងមីងទៅនៅណាវិញ?

ម៉ាចៈ ខ្ញុំទៅនៅណងចាន់ទៅបើកអង្គរហូបនៅនោះឯង ។

វណ្ណៈ ណងចាន់នៅណាទៀតហើយ?

ម៉ាចៈ ខ្ញុំទៅជាវខ្ញុំទៅធ្វើស្រែបានជាមួយមីងមាហើយខ្ញុំទៅនៅជាំជាមួយគេ ។

វណ្ណៈ អត់ទេ ខ្ញុំចង់និយាយចេះ មីងនិយាយមួយៗ?

ម៉ាចៈ ចាស ។

វណ្ណៈ ព្រោះនៅឆ្នាំ៧៥ ខ្មែរក្រហមពេញធីងហើយ មិនទាន់ទៅនៅណងចាន់អីទេ ចឹងចង់និយាយថាឆ្នាំ១៩៧៥ហ្នឹង ។

ម៉ាចៈ ចាស ។

វណ្ណៈ ខ្មែរក្រហមទើបចូលទីក្រុងភ្នំពេញបានទេ?

ម៉ាចៈ ចាស ។

វណ្ណៈ ហើយចឹងទៅឆ្នាំ៧៥-៧៦-៧៧-៧៨និង៧៩ ចឹង៧៩បានវៀតណាមចូលមក?

ម៉ាចៈ ចាស!វៀតណាមចូល ។

វណ្ណៈ ចឹងខ្ញុំចង់សួរថាឆ្នាំ ឆនាំ៧៦-៧៧-៧៨ហ្នឹងមីងនៅណានៅភូមិណា?

ម៉ាចៈ ខ្ញុំនៅភូមិចាហួយហ្នឹងឯង ខ្ញុំនៅជាមួយអ៊ឹមីងមាហ្នឹងឯង ។

វណ្ណៈ ភូមិចាហួយនៅណាវិញ?

ម៉ាចៈ ភូមិចាហួយនៅជិតមោងហ្នឹង ។

វណ្ណៈ ចឹងកាលមីងថានៅកំពតនៅឆ្នាំណាវិញ?

ម៉ាចៈ កំពតខ្ញុំទៅលេងម្តងម្កាល ។

វណ្ណៈ ចឹងទៅលេងទេ?

ម៉ាចៈ ចាស!ទៅលេង ។

វណ្ណៈ ចឹងមីងជំនាន់បីឆ្នាំមីងនៅមោង?

ម៉ាចៈ ចាស!នៅមោង តែគេឲ្យទៅវែកដីនៅកងចល័តណាស់លោកគ្រូ ។

វណ្ណៈ ចឹងពីឆ្នាំ៧៥ដល់៧៩នៅមោង?

ម៉ាចៈ ចាស!នៅចល័តវែកដី កោះស្វា បាក់នឹមអី ដើរវែកតែដីក្បាលជន្លង់ធំជាងក្បាល ។

វណ្ណៈ វែកដីនៅណា?

ម៉ាចៈ ខ្ញុំរែកដីនៅលាចដំណាក់ក្រមនោះ ខ្ញុំនៅមោងឫស្សីហ្នឹងរែកដីដើរកងចល័តគ្រប់កន្លែងមិនដែលបាននៅផ្ទះសមរភូមិក្រោយហ្នឹងគេទេ នៅកងចល័តដើរដេកនៅដីមិនដែលមានផ្ទះអីហ្នឹងគេទេ យប់ណាដេកហ្នឹង ។

វណ្ណៈ ចឹងការហូបចុកយ៉ាងម៉េចដែរ?

ម៉ាចៈ មានអីហូបទេ អង្ករ៥កំប៉ុងគ្នា១០០នាក់នោះបបរ បានបាយទាំងទឹកទាំងកាកមួយវែកប៉ុណ្ណោះឯង មិនដែលមានអីហូបទេ មិនដែលហូបឆ្អែតទេ ។

វណ្ណៈ ប្រធានកងចល័តពីណាគេ?

ម៉ាចៈ កាលហ្នឹងឈ្មោះ គ្រូវឿនៗប្រធានកងចល័ត ។

វណ្ណៈ ចឹងគ្រូវឿនហ្នឹងមកពីខាងណា?

ម៉ាចៈ គ្រូវឿនហ្នឹងនៅស្រុកហ្នឹងឯង ។

វណ្ណៈ ចឹងកាលហ្នឹងមីងនៅតំបន់ប៉ុន្មាន?

ម៉ាចៈ ខ្ញុំកាលនៅមោងហ្នឹងមិនដឹងជាតំបន់ប៉ុន្មានទេ មិនដឹងជាតំបន់២ឬតំបន់៤ទេ ខ្ញុំភ្លេចហើយព្រោះយូរដែលហើយ ។

វណ្ណៈ ចឹងមីងនៅហ្នឹងរយៈពេលបីឆ្នាំហ្នឹងមីងនៅជីកទំនប់លើកប្រឡាយរហូត?

ម៉ាចៈ ចាស!ជីកទាល់តែវៀតណាមចូលបែកផ្លូវគ្នាតែម្តង ទាំងគ្រូទាំងកូនសិស្សមិត្តចុះមកក្រោមវិញ បែកវៀតណាមចូលហ្នឹងរត់ចុះមកក្រោមវិញ រត់មករកស្រុកភូមិវិញអត់បានឡើងលើភ្នំទេ ។

វណ្ណៈ ចឹងកាលឆ្នាំ១៩៧៩មីងរត់ទៅណា?

ម៉ាចៈ ខ្ញុំរត់ក្រឡឹងតែក្នុងស្រុកភូមិហ្នឹង មិនបានហ៊ានឡើងទៅភ្នំអីខ្លាចអត់មានបាយទឹក ។

វណ្ណៈ ចឹងមានន័យថាមិនបានរត់ទេ?

ម៉ាចៈ ចាស!មិនបានរត់ទេ នៅក្នុងស្រុកក្នុងភូមិគេច គេចនៅស្រុកភូមិហ្នឹង ។

វណ្ណៈ ចឹងនៅក្នុងភូមិហើយយ៉ាងម៉េចទៀតនិយាយមើល?

ម៉ាចៈ កាលវៀតណាមចូលទៅមានធ្វើបាបទុក្ខទោសអីទេ នរណានៅណានៅទៅតាមផ្ទះតាមភូមិហ្នឹងក៏គ្មានបានវៃបានសម្លាប់អីទៀត វៀតណាមចូលហើយស្រួលរហូត ដើរប្រូតដើរបូតធ្វើស្រែបានតាមចិត្តបាយបានឆ្អែតវិញ ។

វណ្ណៈ ចឹងជំនាន់ខ្មែរក្រហមមីងមានដឹងថាប្រជាជនអត់បាយច្រើនទេ?

ម៉ាចៈ ជំនាន់ខ្មែរក្រហមហ្នឹងវាអត់ហើយលោកគ្រូ វាមិនដែលមានអីហូប ។

វណ្ណៈ៖ ចឹងកាលហ្នឹងមីងមានដឹងថាខ្មែរក្រហមចាប់មនុស្សយកទៅសម្លាប់អីមានដឹងទេ?

ម៉ាចៈ បើរត់ទៅចាប់បានតាមផ្លូវវាបាញ់ចោល វាអត់មានទុកទេវាតាមទាន់ត្រង់ណាសម្លាប់ចោលត្រង់ហ្នឹង ។

វណ្ណៈ៖ អត់ទេ ខ្ញុំចង់និយាយកាលបីឆ្នាំដូចថាប្រជាជនកំពង់តែធ្វើស្រែលើកទំនប់ប្រឡាយចឹងមានអង្គការមកចាប់អ្នកនេះចាប់អ្នកនោះអីទេ មីងមានបានដឹងទេ?

ម៉ាចៈ មានតែរឿងកាប់ចាក់គ្នាអ្នកធំអ្នកតូចដូចថាឈ្លបឃុំ ដូចជាធ្វើគណៈឃុំអីប្រជាជនដែលខឹងតាមសម្លាប់វិញ វាសឹកដែលធ្វើបាបវាកាលជំនាន់បីឆ្នាំវាអត់ឃ្លាននោះ ។

វណ្ណៈ៖ តែខ្ញុំចង់និយាយជំនាន់បីឆ្នាំសិន កាលជំនាន់ខ្មែរក្រហមមេកងអីមានចាប់អ្នក១៧មេសាយកទៅសម្លាប់ចោលទេមីង?

ម៉ាចៈ បើនិយាយសម្លាប់ជំនាន់ហ្នឹងលោកគ្រូអើយ ដីចាហួយពោធិសាត់ហ្នឹងថាត្រង់ណាក៏រណ្ដៅខ្មោចដែរ ។

វណ្ណៈ៖ ចាហួយពោធិសាត់ឬក៏បាត់ដំបង?

ម៉ាចៈ ខេត្តជាមួយគ្នាហ្នឹងឯង ចាហួយប្រឡោមក្នុងហ្នឹងឯង ខេត្តជាមួយគ្នាទាំងអស់ លោកគ្រូណែករឿងវ៉ៃចោលវាចាប់បានវាវ៉ៃចោល វាវ៉ៃចោលពេញៗរណ្ដៅ ។

វណ្ណៈ៖ ចឹងមីងមានដែលឃើញគេវ៉ៃទេ?

ម៉ាចៈ ខ្ញុំបានឃើញច្បាស់នេះដំបងឆ្នូងប៉ុនៗមេដើង ខ្ញុំនៅស្រុកភូមិនោះឯងឈាមកាត់ៗថ្កុកតែខ្ញុំមិនដែលរឿងដឹងខ្លាចគេ ។

វណ្ណៈ៖ យ៉ាងម៉េចបានជាមីងឃើញ?

ម៉ាចៈ ចុះគេយកទៅវ៉ៃចោលខ្ញុំក្មេងៗដើរតាមតែផ្លូវខ្ញុំមិនដែលហ៊ានដើរឆ្វេងស្ដាំណាបើគេយកទៅវ៉ៃចោល ខ្ញុំខ្លាចមួយយប់ៗដេកមិនដែលហ៊ានព្រុមាត់ទេខ្លាច ខ្លាចគេនិយាយអីគេយកទៅវ៉ៃចោលមិនហ៊ាន មិនហ៊ាននិយាយរើងពីនេះពីនោះមិនដែលហ៊ានទេ ខ្លាចគេព្រុគេវ៉ៃចោលទាំងគ្រួសារឲ្យតែព្រុ ។

វណ្ណៈ៖ ចឹងមីងនៅក្មេងកាលហ្នឹងមីងដើរទៅគេអត់ប្រកាន់?

ម៉ាចៈ គេអត់ប្រកាន់ទេ បើវ៉ៃឈ្មោះ «ខ» ចឹងចំឈ្មោះ«ក» ចឹងយកទៅវ៉ៃទាំងគ្រួសារយកទៅវ៉ៃចោល ។

វណ្ណៈ៖ ចឹងថាម្ដាយមីងស្លាប់ដោយអត់អាហារតាំងពីឆ្នាំណា?

ម៉ាចៈ ឆ្នាំ៧៦ ។

វណ្ណៈ	ចឹងឪពុក?

ម៉ាចៈ	ឪពុកខ្ញុំស្លាប់តាំងពី៧២ជំនាន់លន់ នល់នោះ ។

វណ្ណៈ	បាទ ។

ម៉ាចៈ	គាត់ស្លាប់ដោយសារជំងឺគ្រុនចាញ់ ចាញ់ស្រុកលើនោះឯងគាត់ទៅកាប់គាស់ចំការដាំដុះ ដាំស្រូវដាំអីហូបធ្វើស្រែដាំស្រូវគាត់ចាញ់នៅហ្នឹង បើម៉ែឪស្លាប់នៅឆ្នាំ៧៦ជំនាន់ប៉ុល ពត ។

វណ្ណៈ	ចឹងបងៗស្លាប់ក្រោយទៀត?

ម៉ាចៈ	បងៗខ្ញុំទើបស្លាប់កាលវៀតណាមចូល ចូលធ្វើទាហានបងខ្ញុំ៤នាក់អ្នកតស៊ូទាំងអស់នៅ តែកូនពៅខ្ញុំស្រីនេះឯង ពោះមួយ៤នាក់ប្រុសស្លាប់ទាំងអស់ ធ្វើទាហានខ្ញុំកំសត់កម្រ ណាស់លោកគ្រូអើយ ព្រាត់ខ្ចាតខ្ចាយចេញពីស្រុកមក មកដល់ស្រុកគេនេះខ្ញុំកំព្រាមក តាមគេ គេថាអីណារកស៊ីស្រួលចេះតែមកហើយ មកតាមមីងមាស្រុកភូមិមកស្រុកគេ នេះមក ដល់មកទៅវាមិនមានរបស់របរអីធ្វើ មានស្រែចំការបន្តិចបន្តួចវាមិនមានរបស់ អូសទាញណាលោកគ្រូ ។

វណ្ណៈ	បាទ ។

ម៉ាចៈ	ដើរស៊ីឈ្នួលគេបាន១០បាន៩ចិញ្ចឹមកូន ។

វណ្ណៈ	មីងចឹងកាលឆ្នាំ៧៩ ៨០-៨១-៨២អីមីងនៅស្រុកភូមិឬមួយមីងចេញទៅខាងណាៗ ទៀតហើយ?

ម៉ាចៈ	ខ្ញុំទៅលេងស្រុកនោះបានបីបួនប្រាំឆ្នាំប៉ុណ្ណោះឯងលោកគ្រូ ទៅលេងស្រុកម៉ែខ្ញុំគាត់កើត នៅស្រុកកំពតនោះហើយ គាត់មានប្ដីខ្ញុំមិនទាន់ចាប់ភពមកគាត់ការហើយមកនៅស្រុក មោងចាហួយប្រឡោមភ្លុកនេះណាស់លោកគ្រូ បានដឹងថាគាត់កើតខ្ញុំក៏កើតនៅស្រុកនេះ ដែរ កើតនៅចាហួយប្រឡោមភ្លុកនេះដែរ ។

វណ្ណៈ	ចឹងកាលមីងរៀបការនៅឆ្នាំណាដែរ?

ម៉ាចៈ	ខ្ញុំការថ្ងៃ១៣កើតខែកត្ដិកមិនជាឆ្នាំអី ។

វណ្ណៈ	ចឹងកាលការហ្នឹងមានអ៊ុនតាក់មកហើយនៅ?

ម៉ាចៈ	មកហើយមកឡើងអ៊ុនតាក់ៗ ។

វណ្ណៈ	ការមុនអ៊ុនតាក់ឬក្រោយ?

ម៉ាចៈ	មុនអ៊ុនតាក់មក ។

វណ្ណៈ៖ ការនៅណា?

ម៉ាចៈ ការនៅបន្ទាយឆ្មាហ្នឹង ការនៅផ្ទះបងត្រង់ហ្នឹងខាងត្បូងហ្នឹងណាស់ ។

វណ្ណៈ៖ ចឹងបន្ទាយឆ្មាហ្នឹងមីងមកតាំងពីឆ្នាំណា?

ម៉ាចៈ បន្ទាយឆ្មាហ្នឹងមិនដឹងជាខ្ញុំមកតាំងពីឆ្នាំ៧០ប៉ុន្មាន ខ្ញុំមកជាមួយពួកគា អ៊ីតហ្នឹងខ្ញុំមកតាំងពីក្រមុំឥឡូវអាបងគេអាយុ១២ឆ្នាំ អាតូចនោះ៧ឆ្នាំហើយ ។

វណ្ណៈ៖ ចឹងកាលឆ្នាំ៨២-៨៣-៨៤-៨៥-៨៦-៨៧-៨៨អីហ្នឹងមីងនៅណាចេញពីបាត់ដំបងហើយនៅ?

ម៉ាចៈ កាលហ្នឹងខ្ញុំចេញពីស្រុកហ្នឹងហើយ ខ្ញុំចេញពីស្រុកចាហួយហ្នឹងហើយ ។

វណ្ណៈ៖ ឆ្នាំណាដែលមីងចេញ?

ម៉ាចៈ ខ្ញុំចេញទៅនៅកំពតហ្នឹង ស្នាក់នៅជាមួយបងប្អូននោះ ។

វណ្ណៈ៖ ចឹងពេលវៀតណាមចូលហើយមីងនៅកំពតទៀត?

ម៉ាចៈ ខ្ញុំទៅពីរដងខ្ញុំទៅលេង ទៅនៅទៅលេងបងប្អូនស្រុកកំណើតម៉ែឪហ្នឹងខ្ញុំទៅលេងហ្នឹងបាន ខ្ញុំមិនដឹងជា៧០ប៉ុន្មានព្រោះកាលហ្នឹងខ្ញុំនៅស្ទើរៗមិនសូវដឹងគិត ខ្ញុំមកនៅនេះយូរហើយ តាំងពីសម័យអ៊ុនតាក់មកនៅវត្ត នៅពេញវត្តពេញអីមុនអ៊ុនតាក់ ។

វណ្ណៈ៖ មុនយូរទេ ពេលមីងមកនៅហ្នឹងមានវៀតណាមវ៉ៃជាមួយខ្មែរក្រហមអីពេញហ្នឹងមីងនៅហ្នឹងទេ?

ម៉ាចៈ ខ្ញុំវៀតណាមនៅទំនប់លាវនោះហើយ កាលហ្នឹងយួននៅពេញហ្នឹងទាំងអស់ទំនប់លាវហ្នឹងទាំងអស់ ។

វណ្ណៈ៖ ចឹងមីងចេញពីបាត់ដំបងមកតាំងពីឆ្នាំ៨០-៧៩អីដែលចឹង?

ម៉ាចៈ ចាស!ខ្ញុំមកនៅមានវៀតណាមនៅ ។

វណ្ណៈ៖ ចឹងយ៉ាងម៉េចបានជាមីងមិននៅស្រុកបានជារត់មកនៅទីនេះវិញ?

ម៉ាចៈ ខ្ញុំថាស្រុកនេះវាសម្បូរស្រែធ្វើ ។

វណ្ណៈ៖ ចឹង?

ម៉ាចៈ ចាស ។

វណ្ណៈ៖ ចឹងកាលហ្នឹងនៅខាងនេះគេហៅថាតំបន់ខ្មាំងហើយកាលហ្នឹង?

ម៉ាចៈ ចាស ។

វណ្ណៈ៖ គេតំបន់ខ្មាំងហើយចោទគ្នាទៅវិញទៅមកចឹង?

ម៉ាចៈ ចាស!មកហ្នឹងមិនទាន់ចប់សង្គ្រាមទេ នៅចំកន្លែងច្បាំងគ្នាដេកមិនដែលបានលក់ទេ មិនដែលហ៊ានដេកលើផ្ទះទេ ដេកតែត្រង់សេ ត្រង់សេមិនទាន់លុបផង ពួគ្គងមកហកចូលក្រឡុកបណ្តោយ ។

វណ្ណៈ ចឹងប្រហែលជាឆ្នាំ៨០-៨១មីងមកនៅហ្នឹងតែម្តង?

ម៉ាចៈ ចាស!វាយូរណាស់ហើយតាំងពីមុនអ៊ុនគាត់ ។

វណ្ណៈ ចឹងកាលមីងមកហ្នឹងនៅក្រមុំនៅឡើយទេ?

ម៉ាចៈ នៅក្រមុំ ។

វណ្ណៈ មកនៅហ្នឹងមកនៅជាមួយពីណាគេ?

ម៉ាចៈ នៅជាមួយបងអ៊ុប បងអឺ ត្រូវជាបងប្អូនជីដូនមួយមកនៅជាមួយគាត់តាំងពីក្រមុំ កាលមកនៅហ្នឹងវ៉ាន់ព្រៃស្តុកណែនប៉េះមិនហ៊ានចូលទេ ។

វណ្ណៈ ក្រែងនៅហ្នឹងវាលទេ?

ម៉ាចៈ សុទ្ធតែព្រៃទាំងអស់ សុទ្ធតែព្រៃលោកគ្រូ ។

វណ្ណៈ ចឹងមានព្រៃដើមឈើធំៗទេ?

ម៉ាចៈ មានដើមឈើធំៗហ្នឹងឯង គ្រាន់តែនៅក្នុងប្រាសាទនេះមានព្រៃខ្លាព្រៃដំរីលោកគ្រូព្រៃក្នុងប្រាសាទនេះ ព្រៃឡើងណែនប៉េះ ។

វណ្ណៈ មានដំរីដែរ?

ម៉ាចៈ កាលពីសម័យសង្គមមានទាំងដំរីខ្លាណាលោកគ្រូនេះណាស់ ព្រៃខ្លាព្រៃដំរីណាស់ ត្រង់ណាក៏មីនៗខ្ញុំមកនៅនេះ ។

វណ្ណៈ ចឹងសម្បូរមីនដែរ?

ម៉ាចៈ មីន កុំបានអង្គការស៊ីម៉ាកមកដោះហ្នឹងមិនបាច់អី មួយថ្ងៃផ្ទុះងាប់ក្របីពីរបី ។

វណ្ណៈ ចឹងជំនាន់ប៉ុល ពតមីងមានបានដឹងថាមានភូមិមានសហករណ៍ទេ?

ម៉ាចៈ តានេះគាត់នៅស្រុកនេះ "អ្នកជិតខាងនិយាយ" សម័យប៉ុល ពតមានចុះឯង ។

វណ្ណៈ ចឹងកាលសម័យបីឆ្នាំរបបហូបចុកនៅហ្នឹងយ៉ាងម៉េចដែរ?

ម៉ាចៈ អត់ទេប្រមូលគេភូមិធំនោះលោកគ្រូ ។

វណ្ណៈ ចឹងខ្ញុំសួរមីងវិញ ចឹងកាលមីងមកដល់ដំបូងហ្នឹងមានព្រៃមិនសូវមានផ្ទះសំបែងទេ?

ម៉ាចៈ មិនសូវមានទេ ផ្ទះមានមួយៗទេ ។

វណ្ណៈ ចឹងនៅពេលដែលកងទ័ពវៀតណាមវៃចូលមកទៅមីងមានគ្រង់សេក្រាបឬមួយរត់ទៅតាមខ្មែរក្រហមប៉ុលពតអី?

ម៉ាចៈ អត់មានរត់ទៅណាទេ នៅស្រុកភូមិធ្វើតែគ្រង់សេអត់មានទៅណាទេ លោកគ្រូ ។

វណ្ណៈ បាទ ។

ម៉ាចៈ នៅតែតាមផ្ទះតាមគ្រង់សេ ។

វណ្ណៈ ចឹងប្រជាជននាំគ្នាចូលគ្រង់សេ?

ម៉ាចៈ ចាស ។

វណ្ណៈ ចឹងពេលវៀតណាមវៃចូលក្នុងភូមិចឹងមានដែលមកធ្វើបាបប្រជាជនទេ?

ម៉ាចៈ គេដើរតែគេទៅ បើខ្មែរក្រហមបើវាចូលឲ្យវៀតណាមនេះ ខ្មែរក្រហមចូលមកវាដើរដុតផ្ទះសុំលុយ សុំណាបានអត់ដុត មួយចឹងសុំ៥០០ៗបើអត់បានវាដុតផ្ទះនឹម ។

វណ្ណៈ ចឹងមានអ្នកខ្លះថាខាងប៉ុលពតខ្លះថាខ្មែរក្រហម?

ម៉ាចៈ ខ្មែរក្រហមតែម្ដង ខ្មែរក្រហមឡើងដុតតែម្ដង ផ្ទះជាប់គ្នានេះ ។

វណ្ណៈ ចឹងពេលខ្មែរក្រហមវៃចូលវិញ ចឹងខ្មែរក្រហមអត់មានសន្សំសុខជាមួយប្រជាជនទេដើម្បីស៊ើការណ៍ពីវៀតណាមទេ វាមិនមានស៊ើបការទៅវិញទៅមក?

ម៉ាចៈ ទាញលុយមិនបានពីប្រជាជនដុតផ្ទះប្រជាជនចោលមិនមែនតិចខ្នងទេ លោកគ្រូតា អ៊ីបក៏នេះ តា ដែលក៏នេះ ម្ដុំយើងហ្នឹងនេះ១០ខ្នង សុទ្ធតែផ្ទះពីរខ្នងឆេះទាល់តែអស់ ខ្មែរក្រហមដុត ទឹងសុំលុយមិនបានដាក់ទឹម១១នេះខ្ទិច មានអីហ៊ានចេញពីគ្រង់សេលោកគ្រូអើយ នៅតែក្នុងគ្រង់សេហ្នឹងក្រាបឲ្យសំប៉ុត ។

វណ្ណៈ ចឹងនៅពេលដែលទាហានខ្មែរក្រហមទាហានប៉ុលពតវៃទាហានវៀតណាមថយទៅវិញ ពេលចូលមកដល់ក្នុងភូមិហ្នឹងដើរសុំលុយចាប់គោក្របីរបស់ប្រជាជនឬអត់ទេ?

ម៉ាចៈ មិនយកទេ រឿងគោក្របីអីមិនយកទេ ។

វណ្ណៈ តែផ្ទះមីងនៅកន្លែងនេះគាត់ថាយកគោគាត់អស់ពីរនឹមដែលតើ?

ម៉ាចៈ "អ្នកជិតនិយាយ" ខាងខ្ញុំទេដែលយក យករបស់ខ្ញុំហ្នឹងប៉ុលពតអ្នកយកខាងខ្ញុំនោះ ។

វណ្ណៈ នេះផ្ទះគាត់នេះ ផ្ទះគាត់នេះ?

ម៉ាចៈ ផ្ទះយាយនឿមជីង ។

វណ្ណៈ ហ្នឹងហើយគាត់ថាខាងប៉ុលពតចូលគឺយកគោអ្នកស្រុកអីទៅ ហើយបើវៀតណាមចូលមកគ្រាន់ ។

ម៉ាចៈ	“អ្នកជិតនិយាយ”កាលគេយកគោនោះ គោខ្ញុំហ្នឹងឯង ផ្ទះខ្ញុំនៅនោះយករបស់ខ្ញុំហ្នឹងឯង កាលនោះដល់រដូវដឹកកណ្ដាប់ចេះឯងលោកគ្រូ ។

វណ្ណៈ៖	ចឹងផ្ទះនេះផ្ទះពូតើអី?

ម៉ាចៈ	ផ្ទះនេះផ្ទះបង ហើយផ្ទះខ្ញុំតូចនេះ ហើយលោកគ្រូឲ្យពោតថ្ងៃមិននេះ ផ្ទះនោះផ្ទះបងខ្ញុំ ។

វណ្ណៈ៖	ចឹងកាលខ្ញុំសម្ភាសន៍ៗផ្ទះបង?

ម៉ាចៈ	បាទ ។

វណ្ណៈ៖	ចឹងមិនមែនផ្ទះពូទេ?

ម៉ាចៈ	បាទ!ខ្ញុំរវល់ទៅដឹកស្រូវឲ្យកូន យកគោរបស់ខ្ញុំនេះឯងហ្នឹងខាងប៉ារា ។

វណ្ណៈ៖	បាទ ។

ម៉ាចៈ	កាលហ្នឹងគេវៃចូលពីកើតមក របួសច្រើនពីកើតមក មកយកគោ ។

វណ្ណៈ៖	ចឹងមីងនៅពេលដែលវៀតណាមវៃមកចឹងប្រជាជនមានរងគ្រោះអីដែរ?

ម៉ាចៈ	ដូចជាមិនសូវត្រូវស្លាប់ឬសូវរបួសអីផង វាវៃមួយប្រ៉ាវចឹងវាដកចេញវាមិនបាននៅជាប់គ្រាន់តែមួយប្រ៉ាវចឹងវាដកចេញអស់ វាមិននៅតតាំងគ្នាវាល់ព្រឹកវាល់ល្ងាចទេ វាដាក់មួយប្រ៉ាវៗចឹងវាដកចេញហើយ ។

វណ្ណៈ៖	ចឹងកាលវៀតណាមវៃហ្នឹងមានវាលខ្លះព្រៃខ្លះ?

ម៉ាចៈ	កាលហ្នឹងវាខ្លះដែលហើយ ។

វណ្ណៈ៖	មានភូមិមានអីហើយ?

ម៉ាចៈ	ចាស!មានភូមិមានអី តែផ្ទះវាមិនសូវញឹកទេ វាលមានមួយៗនៅតែព្រៃទាំងអស់គ្នា វាមិនស្រឡះចឹងទៅរកតែផ្លូវដើរ ដើរជាន់តែដានជើងគ្នាហ្នឹងសុទ្ធតែព្រៃទេ សព្វថ្ងៃបានវាលបានអីបានស្រួលបួល ។

វណ្ណៈ៖	ចឹងអ្នកស្រុកអ្នកភូមិនេះគេច្រើនតែប្រកបមុខរបរអីដែលមីង?

ម៉ាចៈ	មានតែធ្វើស្រែស្រុកនេះនោះ ធ្វើស្រែដាំដំឡូងមីចឹងទៅ គេមានចំការដាំដំឡូងមីខែប្រាំងឡើង ។

វណ្ណៈ៖	ចឹងមានដើរស៊ីឈ្នួលនៅថៃទេ?

ម៉ាចៈ	អឺ!ស្រុកនេះទៅថៃច្រើនគ្នាណាស់លោកគ្រូ មិនសូវនៅស្រុកទេគេទៅតែថៃ ប្រុសៗគេចេញទៅថៃអស់ហើយគេមិនសូវនៅទេ នៅអ្នកតែគេធ្វើស្រែចំការ មុខរបរគេទៅថៃច្រើន ប្ដីខ្ញុំទៅពីរដងធ្លាក់ឡានទាំងពីរដងមិនដែលបានមួយរៀលមកផ្ទះទេ ។

វណ្ណៈ	យ៉ាងម៉េចចឹង?

ម៉ាចៈ	ទៅជាប់គុកនៅថៃ ថៃវៃហើមខ្លួនអស់ ទៅដាំកូនកាស់ហ្យាអីគេម៉េចទេ ទៅជាបលគុកនៅថៃ ថៃវៃឡើងហើយខ្លួន សព្វថ្ងៃមិនមានអីទេលោកគ្រូអើយដើរស៊ីតែឈ្នួលគេ បានមួយថ្ងៃស៊ីមួយថ្ងៃចឹងទៅ មួយថ្ងៃបាន១៥០ចឹងទៅ ។

វណ្ណៈ	បាទ ។

ម៉ាចៈ	យកមកទិញអង្ករទិញអីហូប គ្មានអីទេ ។

វណ្ណៈ	ចឹងពេលទៅរកស៊ីនៅថៃចឹងទៅ យូរៗមកម្តងហើយបានទៅរកវិញទៀតទៅ?

ម៉ាចៈ	ចាស! ទៅបានពីរឆ្នាំមកផ្ទះ ។

វណ្ណៈ	ចឹងទៅយូរៗ ?

ម៉ាចៈ	ចាស!ដល់ទៅពីរឆ្នាំមកផ្ទះទៅក៏មិនបានអីមួយរៀល ជាប់តែគុកគ្រាន់តែជាប់គុកជិតមួយឆ្នាំ ។

វណ្ណៈ	ចឹងយ៉ាងម៉េចបានជាគេចាប់យើងដាក់គុក?

ម៉ាចៈ	ចុះតម្រួតថៃវាដេញ យើងមិនរត់និងគេ គេដេញចាប់ខ្មែរ យើងមិនបានមើលទាន់ថៃចាប់បានដាក់គុក ។

វណ្ណៈ	ចឹងអ្នកនៅស្រុកភូមិនេះច្រើនចេះថៃដែលឬមួយមិនសូវទេ?

ម៉ាចៈ	មិនសូវចេះទេ មិនចេះទេ ចេះតែគាសានគាត់នៅហ្នឹងថៃតែម្តង ។

វណ្ណៈ	បាទ ។

ម៉ាចៈ	គាត់ធ្វើការធ្វើអីនៅស្រុកថៃគាត់ចេះ គាត់ចេះភាសាដូចខ្ញុំវ៉ាន់មិនដឹងភាសាអីមួយម៉ាតទេថៃក៏មិនចេះ ។

វណ្ណៈ	ចឹងមីងមកដល់ឥឡូវមីងមានធ្លាប់មកលេងស្រុកកំណើតអីទេ?

ម៉ាចៈ	បានទៅលេងបានមួយដង ខ្ញុំទៅបានមកវិញពីរឆ្នាំ ឆ្នាំនេះហើយទៅអត់ម៉ែឪចឹងលោកគ្រូអើយទៅក៏មិនមានបងប្អូនណាមានចែកម្នាក់ដុំអី ស្រែចំការអីវាអត់មាន អត់ពីម៉ែឪទៅគេចែកគ្នាអស់ហើយខ្ញុំមានអី ។

វណ្ណៈ	បាទ ។

ម៉ាចៈ	មកបាតដៃទទេមកស្រុកគេ កំព្រាកំសត់តាំងពីសម័យប៉ុល ពតមកដល់សម័យនេះទៀតនៅតែកំសត់ ។

វណ្ណៈ	ចឹងសម័យប៉ុល ពតមីងនៅកងចល័តរហូត?

ម៉ាចៈ ចង់ចល័តរហូតលោកគ្រូ ។

វណ្ណៈ ចឹងមិនមានតួនាទីជាប្រធានអីទេ?

ម៉ាចៈ អត់មានតួនាទីអីទេ ចុះពួកពាយ័ព្យមានអីដល់ពេលនិរតីចូលមកគ្រួតម្តងវៃចោលដូចហាល វៃពួកពាយ័ព្យចោល និរតីចូលមកវៃប្រធានកងគណៈកងអីវៃចោលដូចហាលចឹង ។

វណ្ណៈ ចឹង?

ម៉ាចៈ ចាស ។

វណ្ណៈ ចឹងវៃគ្នា?

ម៉ាចៈ វៃគ្នា គ្រូកម្មាភិបាលអីខាងនិរតីដាក់ភូសយកៗ ។

វណ្ណៈ ចឹងកាលពួកនិរតីមកមីងមានស្គាល់ទេ មីងមានស្គាល់ឈ្មោះវាទេ?

ម៉ាចៈ លោកគ្រូអើយមកព្រឹបៗមិនដឹងជាពីណាពីណី គេមកដល់ធ្វើការយកពួកឯងទៅសម្លាប់ចោលអស់ គេមកកាន់កាប់ម្តង ខ្ញុំកូនមូលដ្ឋានពិតមែន តែវាមិនមានសិទ្ធអីបានធ្វើការងារនៅតែក្រោមគេនៅតែកងចល័តៗ ខ្លាចគេឲ្យញាក់ទម្រើក ។

វណ្ណៈ ចឹងកាលហ្នឹងប្រធានធំៗដែលគេចាប់ទៅហ្នឹងមីងមានស្គាល់ទេ?

ម៉ាចៈ បងខ្ញុំគ្រូគេយកទៅវៃចោលបងចក់ៗ គ្រូកាលជំនាន់ប៉ុល ពត វៀតណាមយកទៅបាញ់ចោលត្រង់ស្ពានស្វាយដូនកែវ ។

វណ្ណៈ ចឹងជំនាន់ប៉ុល ពតមានវៀតណាមចូលមកបាញ់ណាមីង?

ម៉ាចៈ ទេ រត់មកនេះហើយណា ។

វណ្ណៈ ចឹង?

ម៉ាចៈ គេចាប់យកទៅបាញ់ស្ពានស្វាយដូនកែវបងខ្ញុំ ធ្វើគ្រូជំនាន់ប៉ុល ពត បងជីដូនមួយទម្លាក់ទឹកស្ទឹងនោះ ស្ទឹងស្វាយដូចកែវនោះ ។

វណ្ណៈ ចឹងអ្នកធំៗប្រធានពាយ័ព្យមីងមានស្គាល់មានដឹងទេ?

ម៉ាចៈ ខ្ញុំមិនបានស្គាល់គេទេ លោកគ្រូអើយព្រោះអីមិនស្គាល់ឈ្មោះគេ ឃើញគេគ្រាន់តែបងខ្ញុំការហើយត្រឹមចាប់ដៃគ្នាបានតែបីថ្ងៃយកគ្នាទាំងប្តីទាំងប្រពន្ធយកទៅវៃចោល ឃើញគេអូសបងយកទៅវៃចោលដើរចេះ មិនហ៊ានយំ មិនហ៊ានយំទេខ្លាចគេយកទៅវៃចោលទៀត ។

វណ្ណៈ ចឹងខ្ញុំដូចជាអស់សំនួរអីសួរមីង មីងមានអីចង់សួរខ្ញុំទៀត ។

ម៉ាចៈ	មានការអីទេ លោកគ្រូមានតែប៉ុននេះហើយលោកគ្រូសួរពីសម័យហ្នឹងខ្ញុំបានប្រាប់ប៉ុណ្ណឹង ហើយវាមិនមានអីផង ។

វណ្ណៈ	បាន ។

ម៉ាចៈ	ចាស ។

វណ្ណៈ	ចឹងខ្ញុំអរគុណច្រើនហើយ ។

ម៉ាចៈ	ចាស!សុខសប្បាយ ។

**ចប់**